ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តក្រុងព្រះសីហនុ

គណៈកម្មាធិការលទ្ធកម្ម

លេខ : 017/9 កសស.អល

**លទ្ធកម្ម ក.ស.ស**

## សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សំបកកង់រថយន្តគ្រប់ប្រភេទ សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៨

កំពង់ផែស្វយ័តក្រុងព្រះសីហនុសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា: កំពង់ផែស្វយ័តក្រុងព្រះសីហនុនឹងដាក់អោយដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់សំបកកង់រថយន្តគ្រប់ប្រភេទ សម្រាប់ឆមាសទី ២ ឆ្នាំ ២០១៨ ជូនកំពង់ផែស្វយ័តក្រុងព្រះសីហនុ ។

កំពង់ផែស្វយ័តក្រុងព្រះសីហនុបានរៀបចំឯកសារសំរាប់ក្រុមហ៊ុន/សហគ្រាស បំពេញដើម្បីចូលរួមដេញថ្លៃនិងមានដាក់លក់នៅអង្គភាពលទ្ធកម្មនៃនាយកដ្ឋានផែនការ-លទ្ធកម្ម និងស្ថិតិ ដែលមានអាសយដ្ឋាន : កំពង់ផែស្វយ័តក្រុងព្រះសីហនុ ចាប់ពីថ្ងៃ **០២** ខែ **តុលា** ឆ្នាំ **២០១៨** តទៅរៀងរាល់ម៉ោងធ្វើការ ។ ( ទូរស័ព្ទទំនាក់ទំនងលេខ **012 912 034** )

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃ នៅម៉ោង **៣:០០ រសៀល ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨** ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ តាមអាសយដ្ឋានខាងលើ វេលាម៉ោង **៣:០០ រសៀល ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៨** ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃសូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃនិងសាកសួរព័ត៌មានដែលទាក់ទងនឹងការដេញថ្លៃនេះ ។

*ថ្ងៃ សុក្រ ៤រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*

*ខេត្តព្រះសីហនុ,ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៨*

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជាប្រធានអគ្គនាយក**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

PORT AUTONOME DE SIHANOUKVILLE

**លូ គីមឈន់**

ចម្លងជូន

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ